សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## កិច្ចការស្រាវជ្រាវ

# កម្មវត្ថុនៃឧក្រិដ្ឋវិទ្យា

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ:
**-រស់ ឡាលីន** **-លន់ ស៊ីណាត**
**-ស៊ុន ធារី** **-លាម លិះ**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ស៊ិន រិទ្ធ**

ថ្នាក់**បរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ**
ជំនាញ**នីតិឯកជន** ជំនាន់ទី ១០

ឆ្នាំចូលសិក្សា ២០១៣
ឆ្នាំសរសេរកិច្ចការស្រាវជ្រាវ ២០១៤

**រក្សាសិទ្ធិដោយ** Khmer Famous

# អារម្ភកថា

អត្ថបទកិច្ចការស្រាវជ្រាវប្រធានបទ " កម្មវត្ថុនៃឧក្រិដ្ឋវិទ្យា" ដែលស្ថិតក្នុងដៃមិត្តអ្នកអាន ក៏ដូចលោកសាស្ត្រាចារ្យណែនាំកំពុងពិនិត្យមើលនេះ ខ្ញុំបាទសូមអភ័យទោសទុកជាមុនរាល់កំហុសឆ្គង និងការខ្វះខាតដែលកើតមានឡើង ដោយហេតុថាក្រុមខ្ញុំបាទមិនបានធ្វើការសិក្សាស៊ីជំរៅ និងមិនមានឯកសារគ្រប់គ្រាន់ក្នុងការស្រាវជ្រាវនោះទេ។

ការសរសេរកិច្ចការស្រាវជ្រាវនេះគឺជាកាដកស្រង់ និងសង្ខេបតែតាមសៀវភៅឧក្រិដ្ឋវិទ្យាឆ្នាំសិក្សា២០០៦-២០០៧ សាស្ត្រាចារ ស៊ិន រិទ្ធ និងបញ្ចូលគំនិតបន្តិចបន្តួចដែលធ្លាប់បានសិក្សារៀនសូត្រកន្លងមក។ ម្យ៉ាងទៀតការសរសេរអត្ថបទនេះឡើងគឺខ្ញុំបាទបានអានសៀវភៅនីតិព្រហ្មទណ្ឌទូទៅរបស់សាស្ត្រា រុន ពណ្ណារិទ្ធិ ។

ហេតុនេះខ្ញុំបាទសុំទទួលយកនូវគំនិតនៃការរិះគន់ទាំងឡាយណា ក្នុងន័យជួយស្ថាបនានូវកិច្ចការស្រាវជ្រាវមួយនេះ ធ្វើឲ្យកាន់តែមានភាពល្អប្រសើរឡើងបន្ថែមទៀត។ ខ្ញុំបាទក៏សូមអភ័យទោសជាមុននូវរាល់កំហុសដែលអាចកើតមានឡើង ទាំងផ្នែកបច្ចេកទេស និងខ្លឹមសារមួយចំនួននៃអត្ថបទនេះផងដែរ។

ជាចុងបញ្ចប់ខ្ញុំសូមជូនពរដល់មិត្តអ្នកអាន ក៏ដូចសាស្ត្រាចារ្យណែនាំឲ្យជួបតែ សេចក្តីសុខមានសុខភាពល្អ និងសម្រេចបាននូវជោគជ័យគ្រប់កិច្ចការទាំងឡាយ ហើយដើម្បីលើកស្ទួយដល់កាសិក្សាយល់ដឹងដល់កូនខ្មែរជំនាន់ក្រោយឲ្យទទួលបាននូវចំណេះដឹងប្រកបដោយប្រសិទ្ធិភាព និងភាពកាន់តែប្រសើរឡើងមួយកំរិតទៀត។

# មាតិកា

**អារម្ភកថា** ........ i

**មាតិកា** ........ ii

**សេចក្តីផ្តើម** ........ ១

**ផ្នែកទី ១ ៖ សញ្ញាណទូទៅនៃឧក្រិដ្ឋវិទ្យា** ........ ២

១.១. និយមន័យនៃឧក្រិដ្ឋវិទ្យា ........ ២

១.២. ឫសគល់នៃឧក្រិដ្ឋវិទ្យា ........ ២

១.៣. ទំនាក់ទំនងឧក្រិដ្ឋវិទ្យានិងវិទ្យាសាស្ត្រផ្សេងៗ ........ ៣

១.៤. ភារកិច្ចនៃឧក្រិដ្ឋវិទ្យា ........ ៤

**ផ្នែកទី២ ៖ កម្មវត្ថុនៃឧក្រិដ្ឋវិទ្យា** ........ ៥

២.១. ឧក្រិដ្ឋភាព ........ ៥

២.២. បទល្មើស ........ ៦

២.៣. អត្តសញ្ញាណឧក្រិដ្ឋជន ........ ៦

២.៤. មូលហេតុបទល្មើសនិង លក្ខខណ្ឌនៃការប្រព្រឹត្តបទល្មើស ........ ៧

២.៥. ការព្រមាន ........ ៨

**សេចក្តីសន្និដ្ឋាន** ........ ៩

# សេចក្ដីផ្ដើម

ក្នុងការវិភាគឬសិក្សាទៅលើមុខវិទ្យាអ្វីមួយ គេតែងតែទៅផ្ដោតទៅលើកម្មវត្ថុ និងគោលបំណងថារឿងនេះមានន័យយ៉ាងណា។ ដូចគ្នានេះមុខវិទ្យាឧក្រិដ្ឋវិទ្យាជាមុខវិទ្យាមួយដែលមានការស្មុគស្មាញ និងពិបាកយល់ដែលត្រូវការអោយនិស្សិតផ្ដោតអារម្មណ៍និងធ្វើការស្វែងយល់ជាលក្ខណៈឡូសិក ឬស្វែងយល់តាមបែបទស្សនវិទ្យា។ វិធីសាស្ត្រឧក្រិដ្ឋវិទ្យាជាក្បួន មធ្យោបាយ និងជាឧបករណ៍សម្រាប់ស្រាវជ្រាវវិភាគពី ឧក្រិដ្ឋភាព មូលហេតុនិងលក្ខខណ្ឌរបស់ឧក្រិដ្ឋភាព និងកាបង្ការចំពោះបទល្មើស។ ឧក្រិដ្ឋវិទ្យាគឺជាវិទ្យាសាស្ត្រដែលសិក្សាអំពីឧក្រិដ្ឋភាព សិក្សាអំពីអត្តសញ្ញាណឧក្រិដ្ឋជន សិក្សាអំពីមូលហេតុ និងលក្ខខណ្ឌនៃឧក្រិដ្ឋភាព សិក្សាអំពីមធ្យោបាយបង្ការឧក្រិដ្ឋភាព។

នៅក្នុងកម្មវត្ថុរបស់ឧក្រិដ្ឋវិទ្យាគឺមានភាពទូលាយដែលទាមទារអោយយល់ដឹងពីរចំណុច ទីមួយគឺភាពខុសគ្នារវាងឧក្រិដ្ឋវិទ្យា និងវិទ្យាសាស្ត្រដ៏ទៃទៀតដែលមានសញ្ញាណប្រហាក់ប្រហែល ទីពីរគឺមុខវិទ្យាផ្សេងៗជាកម្មវត្ថុឧក្រិដ្ឋវិទ្យា។ ភាពខុសគ្នារវាងឧក្រិដ្ឋវិទ្យានិងវិទ្យាសាស្ត្រដ៏ទៃទៀតដែលមានសញ្ញាណប្រហាក់ប្រហែលគឺឧក្រិដ្ឋវិទ្យានិងនីតិព្រហ្មទណ្ឌ ឧក្រិដ្ឋវិទ្យានិងឧក្រិដ្ឋវិនិច្ឆ័យ ឧក្រិដ្ឋវិទ្យានិងពន្ធនាគារសាស្ត្រ ឧក្រិដ្ឋវិទ្យានិងការបង្ការឧក្រិដ្ឋ ឧក្រិដ្ឋវិទ្យានិងសង្គមវិទ្យាព្រហ្មទណ្ឌ។ នៅក្នុងមុខវិទ្យាផ្សេងៗជាកម្មវត្ថុឧក្រិដ្ឋវិទ្យាមានដូចជាមុខវិទ្យា នរវិទ្យា សង្គមវិទ្យាឧក្រិដ្ឋ ចិត្តវិទ្យាឧក្រិដ្ឋ។ ការសិក្សាប្រៀបធៀប មុខវិទ្យាជាកម្មវត្ថុគោលដែលត្រូវយល់ដឹងពីឧក្រិដ្ឋភាព។

កម្មវត្ថុចំបងនៅក្នុងឧក្រិដ្ឋវិទ្យា ដែលយើងត្រូវសិក្សានៅពេលនេះគឺឧក្រិដ្ឋភាពក្នុងនេះយើងដែលត្រូវយល់ពី មូលហេតុបទល្មើស ការប្រព្រឹត្តបទល្មើស ទប់ស្កាត់បទល្មើស។ អត្តសញ្ញាណឧក្រិដ្ឋជនដែលត្រូវយល់ដឹងពីបុគ្គលិកលក្ខណរបស់មនុស្សដែលមានស្ថានភាពទូទៅ ភេទ អាយុ ស្ថានភាពគ្រួសារ តួនាទីក្នុងសង្គមរបស់មនុស្ស មុងារឬតំណែងក្នុងសង្គម សកម្មភាពចរិយាសាស្ត្រ អត្តចរឹត សីលធម៌ ចំណាត់ថ្នាក់តាមលក្ខខណ្ឌមាន មូលហេតុជីវិត សុខភាព ការងារ ហៃ្សន សរីរាង្គ តំណពូជន៍ អារម្មណ៍ ការឆែវឆាវ ការញៀនជាដើម។ មួយទៀតគឺលក្ខខណ្ឌដែលនាំអោយមានការប្រព្រឹត្តបទល្មើស ហេតុដូចនេះដើម្បីអោយកាន់តែច្បាស់យើងនឹងសិក្សា និងធ្វើការបកស្រាយលំអិតដូចមានខាងក្រោម៖

# ផ្នែកទី ១ ៖ សញ្ញាណទូទៅនៃឧក្រិដ្ឋវិទ្យា

មុននិងធ្វើការសិក្សាពីកម្មវត្ថុឧក្រិដ្ឋវិទ្យាយើងគួរធ្វើការយល់ដឹងថាអ្វីទៅឧក្រិដ្ឋវិទ្យាហើយវាមានមេយធាងឫសគល់ចេញមកពីណាមានទំនាក់ទំនងនឹងវិទ្យាសាស្ត្រដ៏ទៃទៀតយ៉ាងដូចម្តេចដូចនេះយើងខ្ញុំសូមធ្វើការរៀបរាប់ដូចខាងក្រោម៖

## ១.១. និយមន័យនៃឧក្រិដ្ឋវិទ្យា

ឧក្រិដ្ឋវិទ្យា គឺជាវិទ្យាសាស្ត្រសិក្សាពីមូលហេតុ ឬ កាលៈទេសៈដែលជាប្រភពជម្រុញឲ្យមានការប្រព្រឹត្ត បទល្មើសនិងដើម្បីជាមូលដ្ឋានក្នុងការអនុវត្តនយោបាយព្រហ្មទណ្ឌ[1]។

ពាក្យថា "ឧក្រិដ្ឋវិទ្យា" ចាប់ប្រភពមកពីពាក្យពីរៈ

ភាសាឡាតាំង " CRIMEN " មានន័យថា " ឧក្រិដ្ឋ" (បទល្មើស) និង ភាសាក្រិច " LOGOS " មានន័យថា ទ្រឹស្តី ឬ វិទ្យា។ សរុបមកមានន័យថា ទ្រឹស្តីអំពីបទល្មើស ឬ ឧក្រិដ្ឋវិទ្យា។

## ១.២. ឫសគល់នៃឧក្រិដ្ឋវិទ្យា

ការសិក្សាឧក្រិដ្ឋវិទ្យាគឺជាការសិក្សាមេយធាងមួយរបស់នីតិព្រហ្មទណ្ឌពីព្រោះនិតិព្រហ្មទណ្ឌគេត្រូវសិក្សាលើ នីតិព្រហ្មទណ្ឌទូទៅ នីតិព្រហ្មទណ្ឌពិសេស នីតិវិធីព្រហ្មទណ្ឌ នីតិព្រហ្មទណ្ឌអនីតិជន នីតិព្រហ្មទណ្ឌអន្តរជាតិ។ មុខវិទ្យាដែលជាសេនាធិការរបស់នីតិការរបស់នីតិព្រហ្មទណ្ឌដែលមិនអាចខ្វះបានមានដូចជា៖

- ✓ ឧក្រិដ្ឋវិទ្យា
- ✓ ទណ្ឌវិទ្យា
- ✓ ឧក្រិដ្ឋវិច័យ
- ✓ ចិត្តវិទ្យា
- ✓ សង្គមវិទ្យា

✓ នយោបាយព្រហ្មទណ្ឌ

ឧក្រិដ្ឋវិទ្យាជាវិទ្យាសាស្ត្រសម្រាប់សិក្សាពីមូលហេតុ ឬកាលៈទេសៈដែលជាប្រភពជម្រុញឲ្យមនុស្សប្រព្រឹត្តបទល្មើស និងស្វែងរកដំណោះស្រាយដើម្បីកាត់បន្ថយបទល្មើស និងជាមូលដ្ឋានក្នុងការអនុវត្តនយោបាយព្រហ្មទណ្ឌ។

## ១.៣. ទំនាក់ទំនងឧក្រិដ្ឋវិទ្យានិងវិទ្យាសាស្ត្រផ្សេងៗ

ឧក្រិដ្ឋវិទ្យាមានទំនាក់ទំនងជាមួយនិងសង្គមវិទ្យា និងនីតិធំៗមួយចំនួន នៅក្នុងឧក្រិដ្ឋមានទំនាក់ទំនងជាមួយនីតិដូចជាៈ

- ឧក្រិដ្ឋវិទ្យានិងវិទ្យាសាស្ត្រនីតិព្រហ្មទណ្ឌ : ឧក្រិដ្ឋវិទ្យាបានប្រើប្រាស់នូវបណ្តាសញ្ញាណនានាដែលវិទ្យាសាស្ត្រនីតិព្រហ្មទណ្ឌបានលើកឡើងដូចជា និយមន័យនៃបទល្មើស បណ្តារូបភាពប្រភេទនៃបទល្មើសជាក់ស្តែង ជនល្មើស ស្ថានមិនរាងចាល និងការចាត់ទុកទោសទណ្ឌជាវិធានមួយក្នុងការបង្ការនិងប្រឆាំងបទល្មើស។
- ឧក្រិដ្ឋវិទ្យានិងនីតិវិធីព្រហ្មទណ្ឌ : ស្ថាប័នស៊ើបអង្កេតអយ្យការ និងតុលាកានៅក្នុងរឿងក្តីព្រហ្មទណ្ឌនីមួយៗត្រូវស្វែងរកនៅមូលហេតុ និងលក្ខខណ្ឌដែលនាំឲ្យមានការប្រព្រឹត្តបទល្មើស។ កាតព្វកិច្ចនេះត្រូវបានធ្វើដំណើរនៅពេលអនុវត្ត បណ្តាលក្ខខណ្ឌផ្សេងៗគ្នា នៅតំណាក់កាលនីតិវិធី។ ឧក្រិដ្ឋវិទ្យាបានផ្តល់អោយមន្ត្រីមានសមត្ថកិច្ចខាងលើនូវវិធីសាស្ត្រដើម្បីកំណត់ពីមូលហេតុ និងលក្ខខណ្ឌដែលបង្កអោយមានបទល្មើស។
- ឧក្រិដ្ឋវិទ្យានិងនីតិរដ្ឋបាល : ឧក្រិដ្ឋវិទ្យាបានស្រាវជ្រាវនូវភារកិច្ច និងសិទ្ធិអំណាចស្ថាប័នអង្គភាពនៅក្នុងវិស័យរដ្ឋបាលស្រាវជ្រាវបណ្តាតុល្យភាពរវាងការបង្ការបទល្មើស និងការទប់ស្កាត់អំពើល្មើស។

ឧក្រិដ្ឋវិទ្យាមានទំនាក់ទំនងជាមួយនិង បណ្តាមុខវិជ្ជាសង្គមផ្សេងៗទៀត ដូចជាសង្គមវិទ្យា ចិត្តវិទ្យា វិទ្យាសាស្ត្រអប់រំ។

- ឧក្រិដ្ឋវិទ្យានិងសង្គមវិទ្យា : សង្គមវិទ្យាសិក្សាស្រាវជ្រាវអំពីបណ្តាទំនាក់ទំនងសង្គមដូចជាៈ តួលេខនៃការ បែងចែក ពលរដ្ឋ ពលកម្ម រយៈពេលសំរាក់ សិក្សា បណ្តាលក្ខខណ្ឌដែល

បង្ក ឲ្យមាន ណលក្ខណៈពិសេសរបស់ក្រុមមនុស្សសង្គមបុគ្គលឯកជនលក្ខខណ្ឌនៃការរស់នៅ ការអភិវឌ្ឍន៍នៃ ទីប្រជុំជន...ដែល ជាបញ្ហាមានតម្លៃសម្រាប់ ការស្រាវជ្រាវនៃឧក្រិដ្ឋវិទ្យា អំពីស្ថានភាពនៃបទល្មើសដែលបានកកើត នៅ ក្នុង វិស័យទាំងនេះ។

- ឧក្រិដ្ឋវិទ្យា និង វិទ្យាសាស្ត្រអប់រំ : នៅពេលដែលស្រាវជ្រាវអំពីបទល្មើសដែលប្រព្រឹត្តដោយអនីតិជន (កុមារ) បណ្តាបទល្មើសនៅក្នុងជីវភាពនិងដើម្បីដាក់ចេញនូវវធានការពិសេសសម្រាប់បង្កាបទល្មើសនេះត្រូវប្រើ ប្រាស់នូវចំនេះដឹងរបស់វិទ្យាសាស្ត្រអប់រំដែលបានសន្សំបាននៅក្នុងសកម្មភាពអប់រំកុមារ

## ១.៤. ភារកិច្ចនៃឧក្រិដ្ឋវិទ្យា

ភារកិច្ចនៃឧក្រិដ្ឋវិទ្យា ផ្តើមចេញពីភារកិច្ចសំណូមពររបស់កិច្ចការប្រឆាំងបទល្មើស ដែលត្រូវបាន តាក់តែងឡើងនៅក្នុងតំណាក់កាលណាមួយរបស់រដ្ឋនីមួយៗ នៅក្នុងតំបន់ណាមួយជាកំណត់។ បញ្ហា នេះពុំត្រូវបានកើតឡើងច្បាស់លាស់នៅក្នុងផែនការសកម្មភាពណាមួយនៅឡើយ។ ប៉ុន្តែផ្តើមចេញទ្រឹស្តី ទូទៅ នោះឧក្រិដ្ឋវិទ្យារបស់ព្រះរាជាណាចក្រកម្ពុជាមានភារកិច្ចដូចខាងក្រោមៈ

- ទទួល ប្រមូល នូវពិតមានច្បាស់លាស់ និង ពិតប្រាកដរបស់បទល្មើសដែលកើតឡើងនៅក្នុងសង្គម
- បង្ហាញឲ្យឃើញច្បាស់នៅមូលហេតុ និងលក្ខខណ្ឌនៃឧក្រិដ្ឋភាពនៅក្នុងលក្ខខណ្ឌនៃការផ្លាស់ប្តូរនយោ បាយពីរបបបក្សតែមួយមកជារបបសេរីពហុបក្ស ពីសេក្ខផែនការមកសេដ្ឋកិច្ចទីផ្សារសេរី
- ព្យាករណ៍ស្ថានភាពបទល្មើសនាពេលអនាគតខ្លី ឬ វែង(៥ ឆ្នាំ ឬ ១០ ឆ្នាំ) និងរៀបរៀងនូវផែនការសកម្ម ភាពប្រឆាំងនិងបទល្មើសដោយមូលដ្ឋានវិទ្យាសាស្ត្រសមស្របជាមួយស្ថានភាពបច្ចុប្បន្ននៃសង្គម។
- លើកឡើងនូវសំណូមពរ សំណើរជាក់ស្តែង រួមចំណែកក្នុងការធ្វើឲ្យសុក្រិតនូវប្រពន្ធ័ច្បាប់ជារួម និង ដោយឡែកច្បាប់ព្រហ្មទណ្ឌ ដើម្បីលើកកម្ពស់ ពង្រឹការងារគ្រប់គ្រងសង្គមដោយច្បាប់ (នីតិរដ្ឋ) ទប់ស្កាត់ បទល្មើស និង សកម្មភាពអសកម្ម ផ្សេងៗរបស់សង្គម។

- ធ្វើការស្រាវជ្រាវប្រភេទបទល្មើសធ្ងន់ធ្ងរ និង មានលក្ខណៈជាសកលនាពេលបច្ចុប្បន្ន ដូចជា ឧក្រិដ្ឋភាព នៃបទល្មើសពាក់ពន្ធ័និងសារធាតុញៀន អំពើពុករលួយ ប្លន់ សម្លាប់មនុស្ស ស្ថានភាពមិនរាងចាល រត់ពន្ធ ...ហើយទន្ទឹមនិងនេះ លើកឡើងនូវវិធានការដើម្បីប្រឆាំង និង បង្ក្រាបប្រកបដោយលទ្ធផល។

ដើម្បីនុវត្តភារកិច្ចនេះ រដ្ឋត្រូវយកចិត្តទុកដាក់ និង ដាក់ទុនឲ្យបានច្រើនក្នុងកិច្ចការស្រាវជ្រាវ បណ្តាបញ្ហាដែលជាកម្មវត្ថុនៃឧក្រិដ្ឋវិទ្យា កិច្ចនេះទាមទារឲ្យមានកិច្ចសហការរវាងស្ថាប័នអំណាចរដ្ឋ ស្ថាប័នជំនាញ (ក្រសួង យុត្តិធម៌ អយ្យការ តុលាការ...)។

## ផ្នែកទី២ ៖ កម្មវត្ថុនៃឧក្រិដ្ឋវិទ្យា

កម្មវត្ថុចំបងនៅក្នុងឧក្រិដ្ឋវិទ្យាដែលយើងត្រូវសិក្សានៅក្នុងនេះយើងដែលត្រូវយល់ពី ឧក្រិដ្ឋភាព បទល្មើស មូលហេតុបទល្មើស ការប្រព្រឹត្តបទល្មើស ការទប់ស្កាត់បទល្មើស អត្តសញ្ញាណជនល្មើស ដែលត្រូវយល់ដឹងពីបុគ្គលិកលក្ខណៈរបស់មនុស្សដែលមានដូចខាងក្រោម៖

### ២.១. ឧក្រិដ្ឋភាព

ប្រវត្តិសាស្ត្របានបង្ហាញឲ្យឃើញថា បើសង្គមមានការប្រែប្រួលច្បាប់ក៏មានការប្រែប្រួលដែរ។ នេះសបញ្ជាក់ថាបទល្មើសជាបាតុភូតអាស្រ័យ និងសង្គមកម្ម និងកើតឡើងក្នុពេលកំណត់ ហើយមានភាព ខុសៗគ្នាតាមប្រភេទបទល្មើសតាមកម្មវត្ថុដែលបំពានលើតាមតំបន់មានបទល្មើសតិច ឬច្រើន។ នៅក្នុងជីវភាព ជាក់ស្តែងដូចជា នៅកម្ពុជាសព្វថ្ងៃឧក្រិដ្ឋភាពមានការកើនឡើងដោយសន្ទុះយ៉ាងលឿន។ ឧទាហរណ៍: ចោរកម្ម សកម្មភាពពេស្យាចារ ភាពពុករលួយ និងម្យ៉ាងរហូតដល់យើងធ្វើវិសោធនកម្មនៃបទល្មើសដោយបង្កើនស្ថានទម្ងន់ ទោសដើម្បីទប់ស្កាត់ បទល្មើសមួយផ្នែកទៀតបានកើតឡើងដោយសារតែធាតុអវិជ្ជមានក្នុងសង្គម ដូចជាការប្រ មឹក ភាពបញ្ញើរក្អែកការប្រើប្រាស់គ្រឿងញៀនដែលសង្គមមិនត្រូវការ។

ឧក្រិដ្ឋភាពដែលយើងសិក្សានេះគឺវិភាគរកមូលហេតុនិងលក្ខខណ្ឌនៃការបង្កបទល្មើស និងធ្វើការព្រមាន សម្រាប់អនាគតយើងមិនសិក្សាក្នុងនាមជាច្បាប់ព្រហ្មទណ្ឌទេ ហេតុដូច្នេះហើយបានជាវាមិនមែនជានីតិ។

ឧក្រិដ្ឋវិទ្យាខុសពិទស្សន:វិជ្ជា ពីព្រោះវាសិក្សាឧក្រិដ្ឋភាព តាមស្ថានភាពទីកន្លែង និងពេលវេលានៅក្នុង ដែនកំណត់ជាក់លាក់។

## ២.២. បទល្មើស

អត្ថន័យទូទៅ តាមទ្រឹស្តីឧក្រិដ្ឋវិទ្យាគឺជាការសិក្សាបទល្មើសនៅក្នុងយន្តការគឺត្រូវការវិភាគអំពី ច្បាប់។ តាមច្បាប់ព្រហ្មទណ្ឌបទល្មើសគឺសំដៅដល់អំពើទាំងឡាយណាដែលបង្ករគ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សាធារណ:ហើយអំពើរនោះត្រូវបានចែងក្នុងច្បាប់ជាធរមានទើបចាត់ទុកថាជាបទល្មើស។ នៅក្នុងន័យ ឧក្រិដ្ឋ វិទ្យា បទល្មើសត្រូវបានដែលអាចចាត់ទុកថាជាអំពើល្មើសត្រូវមានកត្តារួមផ្សំដូចជាៈ

ក). កត្តាសត្យានុម័ត

ឧក្រិដ្ឋវិទូចាត់ទុកថាបទល្មើសត្រូវតែមាន នៅក្នុងសង្គមដោយមានកត្តាផ្សេងៗគ្នា ដូចជាបាតុភូតធម្មជាតិ កត្តាជីវសាស្ត្រ និង កត្តាសង្គម។ ចំណុចនេះបទល្មើសជា កត្តាសន្យានុម័តដែលគេអាចទប់ស្កាត់បានមួយផ្នែក ហេតុនេះហើយបានជាបទល្មើសកើតឡើង។

ខ). ភាពមិនចុះសម្រុង

អំពើជាកត្តាសត្យានុម័តចែកចេញជាពីរប្រភេទ ទីមួយ ភាពមិនចុះសម្រុងក្នុងសង្គម ទីពីរការប្រែប្រួល។ បុព្វហេតុនៃភាពមិនចុះសម្រុងហើយបង្កជាបទល្មើសគឺ អាស្រ័យនិង ANOMIA ។ តម្រូវការនៃភាពចាំបាច់នេះមាន សម្ពាធទៅលើចិត្តបុគ្គលហើយទាមទារឲ្យបញ្ចេញសកម្មភាព។ ចំពោះការប្រែប្រួល គឺសំដៅទៅលើរបត់ នៃសង្គម មានផ្នែកសេដ្ឋកិច្ច និងការវិវត្តន៍។

## ២.៣. អត្តសញ្ញាណឧក្រិដ្ឋជន

មានសារ:សំខាន់ណាស់នៅក្នុងឧក្រិដ្ឋវិទ្យា បើគ្មានកម្មវត្ថុទេការព្រមានឧក្រិដ្ឋភាពក៏មិនអាចធ្វើទៅកើតដែរ។ អត្តសញ្ញាណឧក្រិដ្ឋជនដែលកម្មវត្ថុឧក្រិដ្ឋវិទ្យាគឺជាជិវប្រវត្តិ និងចិត្តសាស្ត្ររបស់បុគ្គលប្រព្រឹត្តបទល្មើស។ វិធានការទាំងឡាយដែលអនុវត្តចំពោះអត្តសញ្ញាណឧក្រិដ្ឋជន គឺធ្វើឡើងដោយផ្អែក ទៅលើពត៌មានស្តីពីមូលហេតុរបស់បទល្មើស។ ការស្រាវជ្រាវអត្តសញ្ញាណមានទិសដៅវិភាគទៅលើជីវប្រវត្តិ និងចិត្តសាស្ត្ររបស់ឧក្រិដ្ឋជនមុនពេលប្រព្រឹត្តបទល្មើស ពេលប្រព្រឹត្តប

ទល្មើស និងក្រោយពេលប្រព្រឹត្តបទល្មើស។តាមទ្រឹស្តីឧក្រិដ្ឋវិទ្យាគឺជាការសិក្សាទៅលើជនល្មើស ចែកចេញជាពីផ្នែកគឺ

- បុគ្គលិកលក្ខណ:បុគ្គល
- ភាពខាងក្នុងរបស់បុគ្គលដែលសំដៅទៅលើផ្នែកសង្គម

បុគ្គលិកលក្ខណ:បុគ្គល ផ្នែកនេះសិក្សាអំពីចិត្តរបស់បុគ្គល និង អត្តចរិកដែលមានមកពីធម្មជាតិ។

ការសិក្សាពីភាពខាងក្នុងរបស់បុគ្គលគឺត្រូវដឹងពីបុគ្គលិកលក្ខណរបស់មនុស្សដែលមាន ស្ថានភាពទូទៅ ភេទ អាយុ ស្ថានភាពគ្រួសារ តួនាទីក្នុងសង្គមរបស់មនុស្ស មុងារឬតំណែងក្នុង សង្គម សកម្មភាពចរិយាសាស្រ្ត អត្តចរឹត សីលធម៌ ចំណាត់ថ្នាក់តាមលក្ខខណ្ឌមាន មូលហេតុជីវិត សុខភាព ការងារ ហៃរ្បន សរីរាង្គ តំណពូជន៍ អារម្មណ៍ ការផៃវឆាវ ការញៀន ។

## ២.៤. មូលហេតុបទល្មើសនិង លក្ខខណ្ឌនៃការប្រព្រឹត្តបទល្មើស

មូលហេតុ និង លក្ខខណ្ឌឧក្រិដ្ឋភាពមានការវិវត្តន៍ អាស្រ័យទៅនិងស្ថានភាពសង្គមដូចជាៈ

- ស្ថានភាពសេដ្ឋកិច្ច ៖ កាលណាមនុស្សមានការខ្វះខាត ឬភាពទាល់ច្រកអាចអោយមនុស្ស ហានប្រព្រឹត្តល្មើស និងក្លាយជាទម្លាប់។

- ស្ថានភាពនយោបាយរដ្ឋ ៖ កាលណាស្ថានភាពនយោបាយរដ្ឋមិនមានភាពម៉តចតរដ្ឋបាល របស់រាជការមិនបានអនុវត្តត្រឹមត្រូវអ្នកប្រព្រឹតដែលល្មើសត្រូវបានដោះលែងជាហេតុនាំ អោយអ្នកប្រព្រឹត្តមិនរាងចាល សង្គមពិបាកក្នុងការគ្រប់គ្រងការិយាធិបតេយ្យអាចមាន ពាសពេញប្រទេស។

- ស្ថានភាពគ្រួសារ ៖ កាលណាគ្រួសារមានសមាជិកច្រើនពិបាកក្នុងការគ្រប់គ្រង គ្រួសារមាន ភាពក្រីក្រ ឬមេដឹកនាំក្នុងគ្រួសារខ្វះសមត្ថភាពណែនាំកូនអាចអោយកូនដើរផ្លូវខុសនិងអាច ប្រព្រឹត្តល្មើសផ្សេងៗ

ស្ថានភាពទាំងនេះ ជាលក្ខខណ្ឌដែលជំរុញឲ្យមានបទល្មើស រីឯបទល្មើសទាំងនោះមានលក្ខ ណ:ខុសគ្នាទៅតាម ពេលតាមតំបន់ និងតាមកាល:ទេស:ហើយពេលខ្លះទៀតកើតឡើងដោយចៃ ដន្យនិងឱកាសដែលអំណោយផល។

ឧទាហរណ៍ : នៅក្នុងលក្ខខណ្ឌអំណោយផល ដូចជាកាសាងសងផ្ទះដែលអត់មានរបង វាជាលក្ខខណ្ឌដែលអំណោយផលដល់ជនល្មើសក្នុងការចូលលបលួចឬធ្វើសកម្មភាពផ្សេងៗ ។

## ២.៥. ការព្រមាន

ការព្រមានគឺជាវិធានការដែលមានទិសដៅលុបបំបាត់បទល្មើស បំបាត់មូលហេតុដែលនាំឲ្យកើតបទ ល្មើសវិភាគ និងធ្វើការនិទស្សន៍បទល្មើសសិក្សាស្ថិតិនៃបុព្វហេតុជាដើម។

កម្មវត្ថុនៃឧក្រិដ្ឋវិទ្យាទាំងប្រាំ មានទំនាក់ទំនងគ្នាយ៉ាងជិតស្និត ដែលការសិក្សាមិនអាចបោះបង់ណាមួយ បាន ពីព្រោះឧក្រិដ្ឋវិទ្យាស្ថិតក្នុងជំពូកវិទ្យាសាស្ត្រដទៃទៀត ដើម្បីសម្រេចបំណងរបស់ខ្លួន។

# សេចក្តីសន្និដ្ឋាន

ក្រោយពីសិក្សាស្រាវជ្រាវទៅលើកម្មវត្ថុនៃឧក្រិដ្ឋវិទ្យាកន្លងមកយើងឃើញថាវា មានភាពចាំបាច់ណាស់ ពី ព្រោះវាសិក្សាទៅលើ ឧក្រិដ្ឋជន គឺវាបង្ហាញអំពីអត្តចរិករបស់បុគ្គលដែលប្រព្រឹត្តបទល្មើស ណាមួយ ហើយវា អាចឲ្យយើងស្វែងយល់នូវគោលបំណងរបស់ជនល្មើសសញ្ញាណនៃបទល្មើសដែលប្រព្រឹត្តដោយបុគ្គល ដែល ជា ឧក្រិដ្ឋជន។ ម្យ៉ាងទៀតវាជាភាពមិនអាចខ្វះបាននៅក្នុងវិស័យព្រហ្មទណ្ឌដែលត្រូវ តែមានវត្តមាន នៃកម្មវត្ថុ ឧក្រិដ្ឋវិទ្យាគឺដោយសារតែវា ចង្អុលបង្ហាញជនល្មើស មូលហេតុដែលនាំឲ្យមានការប្រព្រឹត្តបទល្មើស និង សិក្សាអំពីចិត្តសាស្ត្ររបស់បុគ្គល គឺសិក្សាទៅលើចិត្តរបស់បុគ្គលដែលដាក់សម្ពាធទៅលើបុគ្គលណាមួយឲ្យប្រ ព្រឹត្តខុសច្បាប់ ឬ ផ្ទុយទៅនឹងច្បាប់។

ដូច្នេះមុខវិជ្ជាឧក្រិដ្ឋវិទ្យា ជាមុខវិជ្ជាមួយដែលនិស្សិតចូលចិត្តផ្នែកព្រហ្មទណ្ឌ ឬ ផ្នែកតុលាការគួធ្វើការស្រាវ ជ្រាវបន្ថែមទៀត នៅលើមុខវិជ្ជានេះ ព្រោះឯកសារជាភាសាខ្មែរនៅខ្វះខាតនៅឡើយ៕